អង្គការសហប្រជាជាតិ

A/HRC/RES/36/32

មហាសន្និបាត

ចែកចាយទូទៅ
៥ តុលា ២០១៧
សំណៅដើម៖ អង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
**សម័យប្រជុំលើកទី ៣៦**
ថ្ងៃទី១១ ដល់ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៧
របៀបវារៈចំណុចទី ១០

# សេចក្តីសម្រេចដែលបានអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០១៧

## ៣៦/៣២ សេវាប្រឹក្សាយោបល់ និងជំនួយផ្នែកបច្ចេកទេសសម្រាប់ប្រទេសកម្ពុជា

*ក្រុមប្រឹក្សាសិទ្ធិមនុស្ស*

*ដោយបញ្ជាក់ជាថ្មី*ថារដ្ឋជាសមាជិកទាំងអស់មានកាតព្វកិច្ចលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដូចមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ ដូចបានបញ្ជាក់ជាថ្មីនៅ ក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស និងស្របតាមកាតព្វកិច្ចរបស់រដ្ឋទាំងឡាយក្រោម កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និងលិខិតុឧបករណ៍សិទ្ធិមនុស្ស ដែលកំពុងស្ថិតនៅជាធរមាន

*ដោយរំលឹកឡើងវិញ*នូវសេចក្តីចិត្តសម្រេចរបស់មហាសន្និបាតលេខ ៦០/២៥១ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦

*ដោយរំលឹកឡើងវិញផងដែរ*នូវសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ៥/១ និងលេខ៥/២ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៧ និងដោយសង្កត់ធ្ងន់ថាអ្នកកាន់កាប់អាណត្តិនីតិវិធីពិសេសទាំងឡាយ ត្រូវបំពេញភារកិច្ចរបស់ខ្លួន ស្របតាមសេចក្តីសម្រេចចិត្តទាំងនោះ និងឧបសម្ព័ន្ធ នោះ។

*ដោយរំលឹកឡើងវិញ*នូវសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ៣០/២៣ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៥ និងសេចក្តីសម្រេចចិត្តពាក់ព័ន្ធផ្សេងទៀត

*ដោយចងចាំក្នុងចិត្ត*នូវរបាយការណ៍របស់អគ្គលេខាធិការស្តីពីតួនាទី និងសមិទ្ធិផលរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងការជួយឧបត្ថម្ភដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្ស។[1]

*ដោយទទួលស្គាល់*ថាប្រវត្តិសាស្ត្រដ៏សោកនាដកម្មនៃប្រទេសកម្ពុជាតម្រូវឲ្យមានវិធានការពិសេសដើម្បីធានាការពារសិទ្ធិមនុស្ស និងការមិនត្រឡប់មកវិញនូវគោលនយោបាយ និងការអនុវត្តពី

[1] A/HRC/36/32.

អតីត កាលដូចមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយដ៏ទូលំទូលាយនៃជម្លោះកម្ពុជា ដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១

*ដោយកត់សម្គាល់*ពីការវិវឌ្ឍថ្មីៗនៅប្រទេសកម្ពុជាជាពិសេស សមិទ្ធផល និងការរីកចម្រើនក្នុងវិស័យសេដ្ឋកិច្ច និងវប្បធម៌នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ តាមរយៈផែនការយុទ្ធសាស្រ្ត និងក្របខណ្ឌជាតិរបស់ខ្លួនដែលពាក់ព័ន្ធ។

*ស្វាគមន៍*ការពិតដែលថាការបោះឆ្នោតឃុំ-សង្កាត់ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ ត្រូវបានប្រារព្ធធ្វើឡើងជាទូទៅប្រកបដោយសន្តិវិធី និងរៀបរយ ហើយថាយុទ្ធនាការឃោសនាបោះឆ្នោតគឺភាគច្រើនគ្មានឧប្បត្តិហេតុ។

១. *អះអាងជាថ្មី*ពីសារៈសំខាន់នៃអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាស្ថាប័នមួយ ឯករាជ្យនិងមិនលំអៀង ហើយជឿជាក់ថា ស្ថាប័នមួយនេះនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការលុបបំបាត់និទណ្ឌភាព និងបង្កើតនីតិរដ្ឋ ដែលក្នុងចំណោមនោះ ដោយប្រើប្រាស់សក្តានុពលរបស់ខ្លួនជាតុលាការគំរូមួយរបស់ប្រទេសកម្ពុជា។

២. *សូមស្វាគមន៍* ការរីកចម្រើនដែលសម្រេចបានទាក់ទងនឹងអង្គជំនុំជំរះវិសាមញ្ញក្នុង តុលាការកម្ពុជា រួមទាំងការចេញសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០១ ប្រឆាំងនឹងអតីតមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យគឺ លោក នួន ជា និងលោក ខៀវ សំផន ដែលបន្ទាប់ពី សាលាឧទ្ធរណ៍បានរកឃើញថាមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិ និងត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ ហើយគាំទ្រជំហររបស់រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិក្នុងន្តការងាររបស់សាលាក្តីនេះប្រកបដោយយុត្តិធម៌ ប្រសិទ្ធភាព និងឆាប់រហ័ស ដោយឃើញពីវ័យកាន់តែទៅមុខ និងសុខភាពទន់ខ្សោយរបស់បុគ្គលដែលត្រូវចោទ និងយុត្តិធម៌ដែលរងចាំជាយូរមកហើយសម្រាប់ប្រជាជនកម្ពុជា។

៣. *សម្តែងក្តីកង្វល់បន្តមានអំពី*ស្ថានភាពហិរញ្ញវត្ថុនៃអង្គជំនុំជម្រះវិសាមញ្ញ ជម្រុញឲ្យរដ្ឋាភិបាលកម្ពុជាធ្វើការជាមួយអង្គការសហប្រជាជាតិ និងរដ្ឋទាំងឡាយដែលផ្តល់ជំនួយដើម្បីធានាបទដ្ឋានខ្ពស់ បំផុតនៃការគ្រប់គ្រងរដ្ឋបាលរបស់អង្គជំនុំជំរះវិសាមញ្ញ ដោយសង្កត់ធ្ងន់ពីសេចក្តីត្រូវការ សម្រាប់រដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ដើម្បីផ្តល់ការជួយឧបត្ថម្ភសមស្របគ្រប់យ៉ាងដល់អង្គ ជំនុំជម្រះវិសាមញ្ញ ហើយសង្កត់ធ្ងន់ផងដែរពីសារៈសំខាន់នៃការគ្រប់គ្រងធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពដោយអង្គជំនុំជំរះវិសាមញ្ញ។

៤. *សូមអំពាវនាវ*ដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យផ្ទេរចំណេះដឹង និងចែករំលែកបទពិសោធន៍ល្អរបស់មន្ត្រីតុលាការនៅអង្គជំនុំជម្រះវិសាមញ្ញ។

៥. *សូមស្វាគមន៍*ការចូលរួមជាវិជ្ជមានរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងដំណើរការពិនិត្យលើក ទីពីរជាសកលតាមកាលកំណត់ និងការទទួលយករបស់រដ្ឋាភិបាលកម្ពុជា នូវអនុសាសន៍ភាគច្រើន ដែលបានធ្វើឡើង និងការរីកចម្រើនរយៈកាលកន្លងមកលើកការអនុវត្តអនុសាសន៍ទាំងនោះ។

៦. *សូមស្វាគមន៍*របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា[2] និងអនុសាសន៍ដែលមានក្នុងរបាយការណ៍នោះ សូមស្វាគមន៍ផងដែរសេចក្តីសន្និដ្ឋាននៅក្នុងខែធ្នូ ឆ្នាំ ២០១៦ នៃអនុស្សារណៈយោគយល់ថ្មីសម្រាប់ការអនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស ស្តីពីសិទ្ធិមនុស្សរវាងរដ្ឋាភិបាល កម្ពុជានិងការិយាល័យប្រចាំរាជធានីភ្នំពេញនៃការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីបន្តអាណត្តិរបស់ការិយាល័យនេះរយៈពេល ២ ឆ្នាំទៀត ដោយកត់សម្គាល់ពីភាពចាំបាច់ ដើម្បីរក្សាការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធ និងដោយគោរពរវាងរាជរដ្ឋាភិបាលកម្ពុជា និង អ្នករាយការណ៍ពិសេសឈានទៅការធ្វើឲ្យកាន់តែប្រសើរឡើងថែមទៀតនូវស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងបន្តកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេសរវាងការិយាល័យឧត្តមស្នងការនិងរដ្ឋាភិបាល និងជម្រុញលើកទឹកចិត្តអ្នករាយការណ៍ពិសេស និង ការិយាល័យប្រចាំរាជធានីភ្នំពេញ ដើម្បីបន្តផ្លាស់ប្តូរព័ត៌មាន ដើម្បីជួយក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃអាណត្តិរបស់ពួកគេរៀងៗខ្លួន ដោយចងចាំក្នុងចិត្តអំពីឯករាជ្យភាពរបស់ពួកគេ

៧. *ជម្រុញលើកទឹកចិត្តឲ្យ* មានការពង្រឹងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និង ការិយាល័យឧត្តមស្នងកា ដូចមានមានចែងក្នុងអនុស្សរណៈយោគយល់គ្នា រវាងរដ្ឋាភិបាល និង ការិយាល័យឧត្តមស្នងការប្រចាំរាជធានីភ្នំពេញ និងអំពាវនាវដល់រដ្ឋាភិបាល អនុវត្តអនុសាសន៍ដែលបានធ្វើឡើងដោយអ្នករាយការណ៍ពិសេស ដោយយកចិត្តទុកដាក់លើបរិបទជាតិរបស់ប្រទេសកម្ពុជា។

៨. *អះអាងជាថ្មី*ម្តងទៀតនូវសេចក្តីត្រូវការសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រឹង និងគោរពតាមនីតិរដ្ឋ រាប់ទាំងតាមរយៈការអនុម័ត ការធ្វើវិសោធនកម្ម និងការអនុវត្តបន្ថែមទៀតនូវច្បាប់និងក្រមច្បាប់សំខាន់ជាសារវ័ន្តសម្រាប់បង្កើតសង្គមប្រជាធិបតេយ្យ និងប្រព័ន្ធតុលាការឯករាជ្យ។

៩. *កត់សម្គាល់*ពីកិច្ចខិតខំប្រឹងប្រែង និងវឌ្ឍនភាពដែលបានធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់កំណែទម្រង់ច្បាប់ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ រួមទាំងការពង្រឹងច្បាប់មូលដ្ឋាន ដូចជានីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌនិង ក្រមព្រហ្មទណ្ឌ

១០. *សូមកត់សម្គាល់ផងដែរ*នូវការអនុវត្តច្បាប់គ្រឹះចំនួន៣ ស្តីពីប្រព័ន្ធតុលាការ ដូចជា ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ និង វិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយស្នើយ៉ាងទទូចដល់រដ្ឋាភិបាលកម្ពុជា ឲ្យបន្តថែមទៀតនូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងកំណែទម្រង់ប្រព័ន្ធតុលាការ រួមទាំង តាមរយៈការអនុវត្តច្បាប់ទាំងនេះប្រកបដោយយុត្តិធម៌ ប្រសិទ្ធភាព និងតម្លាភាព។

១១. *សង្កត់ធ្ងន់*លើតម្រូវការសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការស៊ើបអង្កេតជាបន្ទាន់ និងផ្តន្ទាទោស ស្របតាមនីតិវិធីត្រឹមត្រូវនៃច្បាប់ និងកាតព្វកិច្ចរបស់ខ្លួនក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ អ្នកទាំងឡាយដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ រាប់ទាំងការ

[2] A/HRC/27/70, A/HRC/30/58, A/HRC/33/62 and A/HRC/36/61.

រំលោភសិទ្ធិមនុស្ស សម្តែងពីក្តីកង្វល់យ៉ាងជ្រាលជ្រៅចំពោះមរណភាពរបស់អ្នកវិភាគនយោបាយ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦ និងផលប៉ះពាល់គួរឲ្យភ័យរន្ធត់ដែលអំពើនេះ មានចំពោះសង្គមស៊ីវិល និងសំឡេងឯករាជ្យនៅក្នុងប្រទេសកម្ពុជា អំពាវនាវឲ្យអាជ្ញាធរកម្ពុជា បើកការស៊ើបអង្កេតពេញលេញ និងមានតម្លាភាពលើករណីទាំងនោះ។ និងសង្កត់ធ្ងន់ពីសារៈសំខាន់នៃដំណើរការតុលាការមួយឯករាជ្យពេញលេញនៅក្រោមតុលាការកម្ពុជា។

១២. *កត់សម្គាល់*កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ជម្រុញលើកទឹកចិត្តឲ្យមានការអនុវត្តក្រមព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងអំពើពុករលួយ និង ជម្រុញលើកទឹកចិត្តផងដែរ ឲ្យរដ្ឋាភិបាលបន្តកិច្ចខិតខំប្រឹងប្រែងដូចនេះផ្សេងទៀត ដូចជា តាមរយៈសកម្មភាពការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ

១៣. *ស្វាគមន៍*កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើស ដូចជាការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និង ស្នើយ៉ាងទទូចឲ្យរដ្ឋាភិបាលធ្វើការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីឈានទៅសម្រេចគោលដៅនេះ ដោយសហការជាមួយសហគមន៍អន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងបញ្ហាគន្លឹះលេចធ្លោនៅក្នុងវិស័យនេះ។

១៤. *សូមកត់សម្គាល់*នូវការរកឃើញថ្មីៗបំផុតទាក់ទងនឹងបញ្ហាយេនឌ័រនៅក្នុងប្រទេសកម្ពុជា និងជម្រុញលើកទឹកចិត្តដល់រាជរដ្ឋាភិបាលកម្ពុជាឲ្យពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនលើបញ្ហាយេនឌ័រ រួមទាំងការអនុវត្តច្បាប់ និងបទបញ្ញាដែលមានស្រាប់។

១៥. *ជម្រុញលើកទឹកចិត្ត*ឲ្យរាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំរបស់ខ្លួន ដើម្បីសមភាពយេនឌ័រ លើកកម្ពស់ការផ្តល់សិទ្ធិអំណាចខាងសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយរបស់ស្ត្រី រួមទាំងការចូលរួមរបស់ពួកគេ ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការពង្រីកអត្ថប្រយោជន៍សេដ្ឋកិច្ចរបស់ស្ត្រី តាមរយៈការពង្រឹងលក្ខខណ្ឌការងារ កិច្ចការពារខាងសង្គម និងបទដ្ឋានការងារ

*១៦. ជម្រុញលើកទឹកចិត្តផងដែរ* ក្នុងបរិបទនេះ ឲ្យរាជរដ្ឋាភិបាលកម្ពុជា ឃ្លាំងមើលការអនុវត្តច្បាប់ភូមិបាល ឆ្នាំ២០០១ ដែលរួមមានឧបសគ្គជាក់លាក់ចំពោះស្ត្រី និងក្រុមងាយរងគ្រោះក្នុងការទទួលបានកម្មសិទ្ធិ និងសិទ្ធិដីធ្លី។

១៧. *កត់សម្គាល់*ការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហាដីធ្លី ក្នុងចំណោមបញ្ហាដទៃផ្សេងទៀត តាមរយៈការអនុវត្តច្បាប់ និងបទបញ្ញាពាក់ព័ន្ធ រាប់ទាំងការផ្អាកជាបណ្តោះអាសន្ននូវសម្បទានដីសេដ្ឋកិច្ច និងការចុះបញ្ជីដីធ្លីជាប្រព័ន្ធ សម្តែងពីក្តីកង្វល់ចំពោះបញ្ហាដែលនៅសេសសល់ក្នុងវិស័យនេះ ហើយស្នើយ៉ាងទទូចឲ្យរាជរដ្ឋាភិបាលបន្ត និងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាទាំងនោះឲ្យបានឆាប់រហ័ស និងសមធម៌ ប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌ និងបើកចំហ ដោយពិចារណាអំពីសិទ្ធិ និងផលវិបាកជាក់ស្តែងសម្រាប់ភាគីពាក់ព័ន្ធ និងស្របតាមច្បាប់ និងបទបញ្ញាពាក់ព័ន្ធ ដូចជា ច្បាប់ដីធ្លី ច្បាប់ស្តីពីអស្សាមិករណ៍ និងសារាចរស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋ ដែលត្រូវបានទន្ទ្រានកាន់កាប់ ដោយខុសច្បាប់

តាមរាជធានី ទីក្រុង និងទីប្រជុំជន និងគោលនយោបាយជាតិស្តីពីលំនៅឋាន និងតាមរយៈការពង្រឹងសមត្ថភាព និងប្រសិទ្ធភាពស្ថាប័នពាក់ព័ន្ធ ដូចជា អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មាធិការសុរិយោដីថ្នាក់ជាតិ ខេត្ត និងស្រុក។

១៨. *កត់សម្គាល់ផងដែរ*នូវការសន្យាដែលបានធ្វើឡើង និងការរីកចម្រើនដែលរាជរដ្ឋាភិបាលកម្ពុជា សម្រេចបានក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្រោមសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលកម្ពុជាគឺជារដ្ឋភាគីមួយ និងស្នើយ៉ាងទទូចដល់រដ្ឋាភិបាលឲ្យបន្តចាត់វិធានការ ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រោមសន្ធិសញ្ញាទាំងនោះ ហើយដើម្បីសម្រេចគោលដៅនេះ ពង្រឹងកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយទីភ្នាក់ងារផ្សេងៗរបស់អង្គការសហប្រជាជាតិ រាប់ទាំងការិយាល័យឧត្តមស្នងការ តាមរយៈការបង្កើនកិច្ចសន្ទនា និងការអភិវឌ្ឍន៍សកម្មភាពរួមគ្នា។

១៩. *កត់សម្គាល់បន្ថែមទៀត*ពីការសន្យារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស និងស្នើយ៉ាងទទូចថា កិច្ចការនេះនឹងត្រូវបានធ្វើ ស្របតាមគោលការណ៍ទាក់ទងនឹងឋានៈរបស់ស្ថាប័នជាតិសម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស (គោលការណ៍ទីក្រុងប៉ារីស) និងដោយមានការពិគ្រោះយោបល់គ្រប់គ្រាន់ជាមួយអ្នកពាក់ព័ន្ធ។

២០. *សូមស្វាគមន៍*កិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជាពិសេសក្នុងការដោះស្រាយបណ្តឹងពីឯកត្តបុគ្គល។

២១. *សូមស្វាគមន៍ផងដែរ* កិច្ចខិតខំប្រឹងប្រែង និងការរីកចម្រើនដែលរដ្ឋាភិបាលកម្ពុជាសម្រេចបាន ក្នុងការលើកកម្ពស់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងគោលបំណងដើម្បីសម្រេចបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈការពង្រឹងស្ថាប័នថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន។

២២. *បង្ហាញពីក្តីកង្វល់យ៉ាងធ្ងន់ធ្ងរ*ចំពោះការធ្លាក់ចុះនាពេលថ្មីៗនេះ នូវបរិយាកាសពលរដ្ឋនិងនយោបាយនៅកម្ពុជា ដោយសារតែផលប៉ះពាល់គួរឲ្យភ័យរន្ធត់នៃការផ្តន្ទាទោសតាមផ្លូវតុលាការ និងសកម្មភាពដទៃទៀតប្រឆាំងនឹងសមាជិកគណបក្សនយោបាយ សង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយ ជាពិសេស ការចាប់ខ្លួន និងឃុំខ្លួននាពេលថ្មីៗនេះ នូវមេដឹកនាំគណបក្សប្រឆាំងមួយរូបគឺ លោក កឹម សុខា ហើយអំពាវនាវដល់គ្រប់ភាគីទាំងអស់ ក្នុងចំណោមនោះ គណបក្សកាន់អំណាចឲ្យធ្វើការរួមគ្នា ឈានទៅកាត់បន្ថយភាពតានតឹង និងអំពាវនាវ ដល់រដ្ឋាភិបាលកម្ពុជា ឲ្យធានាការពារសិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិ និងការបង្កើតសមាគម និងបំពេញគណនេយ្យភាពរបស់ខ្លួនសម្រាប់ករណីពាក់ព័ន្ធ។

២៣. *សម្តែងក្តីកង្វល់*អំពីការរឹតត្បិតដែលបានដាក់ទៅ លើប្រព័ន្ធផ្សព្វផ្សាយ សង្គមស៊ីវិល និងគណបក្សនយោបាយ និងផលប៉ះពាល់អវិជ្ជមាននៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងវិសោធនកម្ម ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៧ និងនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ ចំពោះច្បាប់ស្តីពីគណបក្សនយោបាយ និងស្នើយ៉ាងទទូចឲ្យរដ្ឋាភិបាលកម្ពុជា ខិតខំប្រឹងប្រែងជាបន្ត ដើម្បីធានាបរិយាកាសអំណោយផលដល់ការធ្វើសកម្មភាពនយោបាយដោយគណបក្សនយោបាយទាំងអស់ស្ថិតក្រោមគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ហើយត្រូវខិតខំប្រឹងប្រែងថែមទៀត ដើម្បីកែលម្អប្រព័ន្ធបោះឆ្នោត ស្របតាមបទដ្ឋានអន្តរជាតិ ដើម្បីឲ្យដំណើរការនៃការបោះឆ្នោតទាំង មូលរបស់ខ្លួនគួរជាទីពេញចិត្ត និងអាចទទួលយកបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ហើយអំពាវនាវ ឲ្យរដ្ឋាភិបាល

ចាត់វិធានការដើម្បីធានាថា ការបោះឆ្នោតដែលគ្រោងសម្រាប់ខែកក្កដា ឆ្នាំ២០១៨ នឹងប្រព្រឹត្តទៅប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌ និងដោយបើកចំហ។

២៤. *កត់សម្គាល់ដោយក្តីកង្វល់ថា*វិសោធនកម្មឆ្នាំ២០១៧ នៃច្បាប់ស្តីពីគណបក្សនយោបាយអាចនាំឲ្យមានការរឹតត្បិតដោយបំពានលើសកម្មភាពគណបក្សនយោបាយ ជម្រុញលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធទាំងអស់ លើកកម្ពស់ដំណើរការប្រជាធិបតេយ្យដោយសន្តិវិធី ក្រោមនីតិរដ្ឋ និងការប្រកាន់ខ្ជាប់ចំពោះប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស តាមរយៈការចូលរួមពីតំណាងជាប់ឆ្នោតទាំងអស់ក្នុងការជជែកដេញដោលរបស់សភា ស្របតាមរដ្ឋធម្មនុញ្ញ និងអំពាវនាវដល់រដ្ឋាភិបាល កម្ពុជាឲ្យធានាការពារអភ័យឯកសិទ្ធិសភាសម្រាប់គោលបំណងនេះ។

២៥. *ស្នើយ៉ាងទទូចដល់* រដ្ឋាភិបាលកម្ពុជាឲ្យចាត់វិធានការសមស្រប ដើម្បីជម្រុញលើកទឹក ចិត្ត និងផ្តល់លទ្ធភាពដល់សង្គមស៊ីវិល រាប់ទាំងសហជីពកម្មករឯករាជ្យ និងប្រព័ន្ធផ្សព្វផ្សាយ ដើម្បីដើរតួនាទីស្ថាបនាក្នុងការពង្រឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅកម្ពុជា រាប់ទាំងតាមរយៈការធានា និងការលើកកម្ពស់សកម្មភាពរបស់ពួកគេ និងក្នុងការលើកកម្ពស់លទ្ធភាពទទួលបានដោយស្មើភាពគ្នានូវប្រព័ន្ធផ្សព្វផ្សាយដោយគ្រប់ភាគីទាំងអស់

២៦. *កត់សម្គាល់*ថាមានយ៉ាងច្រើននៃអង្គភាពលើសពី ៥.០០០ ដែលប្រតិបត្តិការជាសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ហើយជម្រុញលើកទឹកចិត្តឲ្យរាជរដ្ឋាភិបាលកម្ពុជា យកចិត្តទុកដាក់លើផលប្រយោជន៍ និងកង្វល់របស់អ្នកពាក់ព័ន្ធទាំងអស់ ក្នុងការអនុម័ត និង/ឬ អនុវត្តច្បាប់ និង វិធានការនានា ដែលអាចប៉ះពាល់ដល់សកម្មភាពរបស់សង្គមស៊ីវិល ជាពិសេស ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការលើកកម្ពស់បន្ថែមទៀត នូវសង្គមស៊ីវិលដ៏រស់រវើក និងដើម្បីការពារ និងធានាសេរីភាពក្នុងការបញ្ចេញមតិ ការបង្កើតសមាគម និងការជួបជុំដោយសន្តិវិធី ស្របតាមរដ្ឋធម្មនុញ្ញ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

២៧. *ជម្រុញលើកទឹកចិត្ត*ឲ្យរាជរដ្ឋាភិបាលកម្ពុជាបន្តចាត់វិធានការ ដើម្បីលើកកម្ពស់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ដោយការការពារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រួមទាំង សេរីភាពក្នុងការបញ្ចេញមតិ ហើយដើម្បីសម្រេចគោលដៅនេះ ត្រូវធានាថាច្បាប់ទាំងអស់ត្រូវបានបកស្រាយ និងអនុវត្តនៅក្នុងលក្ខណៈមួយបែបវិនិច្ឆ័យ ដើម្បីលើកកម្ពស់សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ស្របតាមនីតិរដ្ឋ។

២៨. *អញ្ជើញ*អគ្គលេខាធិការ ទីភ្នាក់ងារទាំងឡាយនៃប្រព័ន្ធអង្គការសហប្រជាជាតិ ដែលមានវត្តមាននៅប្រទេសកម្ពុជា និងសហគមន៍អន្តរជាតិ រួមទាំងសង្គមស៊ីវិល ដើម្បីបន្តធ្វើការជា មួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងធានាការការពារ និងលើក កម្ពស់សិទ្ធិមនុស្សរបស់ប្រជាជនគ្រប់រូបនៅប្រទេសកម្ពុជា រួមទាំងតាមរយៈការផ្តល់ជំនួយក្នុងវិស័យទាំងឡាយដូចជា៖

*(ក)* ព្រាងច្បាប់ និងជួយបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យមួយ។

*(ខ)* ការកសាងសមត្ថភាពដើម្បីពង្រឹងស្ថាប័នច្បាប់ ដែលរួមមានការលើកកម្ពស់គុណភាព និងឯករាជ្យភាពរបស់ចៅក្រម ព្រះរាជអាជ្ញា មេធាវី និងបុគ្គលិកតុលាការ ព្រមទាំងទាញយកជំនាញដែលទទួលបានពីបុគ្គលិកជាតិខ្មែរដែលធ្វើការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

*(គ)* ការកសាងសមត្ថភាព ដើម្បីពង្រឹងស្ថាប័នជាតិសម្រាប់ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ និងការអនុវត្តច្បាប់ ក៏ដូចជាការផ្តល់ឧបករណ៍ចាំបាច់សម្រាប់គោលបំណងទាំងនេះ។

*(ឃ)* ការអនុវត្តអនុសាសន៍ដែលបានទទួលយកនៃការពិនិត្យជាសកលតាមកាលកំណត់។

*(ង)* ជួយធ្វើការវាយតម្លៃវឌ្ឍនភាពនៃបញ្ហាសិទ្ធិមនុស្ស។

២៩.*សម្រេច*បន្តរយៈពេលពីរឆ្នាំ នូវអាណត្តិរបស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ហើយស្នើឲ្យអ្នករាយការណ៍ពិសេស រាយការណ៍អំពីការអនុវត្តអាណត្តិរបស់ខ្លួនទៅក្រុមប្រឹក្សាសិទ្ធិមនុស្សនាសម័យប្រជុំរបស់ខ្លួនលើកទីសាមសិបប្រាំបួន និងសែសិបពីរ។ និងដើម្បីចូលរួមក្នុងន័យស្ថាបនាមួយជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឲ្យប្រសើរឡើងថែមទៀតដល់ស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។

៣០.*ស្នើសុំឲ្យអគ្គ*លេខាធិការរាយការណ៍ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៅសម័យប្រជុំសាមសិបប្រាំពីរ និងសែសិបពីររបស់ខ្លួនស្តីពីតួនាទី និងសមិទ្ធផលរបស់ការិយាល័យឧត្តមស្នងការដើម្បីជួយដល់
រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស។

៣១. *ប្តេជ្ញាបន្ត* ការពិចារណារបស់ខ្លួនលើស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា នាសម័យប្រជុំលើកទីសែសិបពីររបស់ខ្លួន។

*កិច្ចប្រជុំលើកទី៤២*
*២៩ កញ្ញា ២០១៧*

[អនុម័តដោយគ្មានការបោះឆ្នោត]